**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

រាជធានីភ្នំពេញ, ថ្ងៃទី.១២.ខែ.វិច្ឆិកា ឆ្នាំ ២០១៤.

លេខ:......៧២......ស.ស.រ

# សេចក្ដីសម្រេច
# ស្ដីពី
# ការតែងតាំងប្រធានគណៈកម្មការ
# បេឡាសង្គ្រោះមន្ត្រីរាជការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២/ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឲប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និង ការ ប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ សេចក្ដីសម្រេចលេខ ៣៧ ស.ស.រ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការបង្កើតគណៈកម្មការបេឡាសង្គ្រោះមន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ ១ .**

ត្រូវបានតែងតាំង **លោក យុន អាន** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ជាប្រធានគណៈកម្មការបេឡាសង្គ្រោះមន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជំនួស **ឯកឧត្ដម ចំរើន វ៉ាន់ថា** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ដែលត្រូវចូលនិវត្តន៍។

ទូរស័ព្ទ / ទូរសា : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្ដម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ប្រការ ២ .**

ប្រធានគណៈកម្មការបេឡាសង្គ្រោះមន្ត្រីរាជការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទើបតែងតាំងថ្មី និងចាស់ត្រូវចុះហត្ថលេខាទទួលស្គាល់លើកំណត់ហេតុប្រគល់ទទួលសមតុល្យទឹកប្រាក់ ដែលមានក្នុងបេឡាឱ្យបានត្រឹមត្រូវ ។

**ប្រការ ៣ .**

នាយកខុទ្ទកាល័យ អធិការ នៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានបេតិកភណ្ឌ និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

ភឿង សកុណា

ចម្លងជូន
- ដូចប្រការ ៣
- គ្រប់អង្គភាពពាក់ព័ន្ធ
  « ដើម្បីជ្រាបជាព័ត៌មាន »
- សាមីខ្លួន « ដើម្បីអនុវត្ត »
- ឯកសារ - កាលប្បវត្តិ